# ថ្នាំបង្ការជំងឺ COVID-19៖ ប្រភេទ Pfizer និងប្រភេទ Moderna
# ពេលវេលានៃការទទួលចាក់ដូសទីពីរ

## តើខ្ញុំគួរទទួលចាក់ដូសទី 2 នៃថ្នាំបង្ការប្រភេទ Pfizer ឬប្រភេទ Moderna នៅពេលណា?




ប្រសិនបើអ្នកទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ឬប្រភេទ Moderna អ្នកនឹងត្រូវចាំបាច់ទទួលចាក់ចំនួន 2 ដូសដើម្បីបញ្ចប់ការចាក់លំដាប់ដំបូង។ ពេលវេលានៃការចាក់ដូសទី 2 របស់អ្នកអាស្រ័យលើស្ថានភាពផ្ទាល់ខ្លួនរបស់អ្នក។

**ប្រសិនបើអ្នកមានអាយុចន្លោះពី 12 ទៅ 64 ឆ្នាំ៖**

- **អ្នកប្រហែលជាអាចទទួលបានអត្ថប្រយោជន៍ពីការទទួលចាក់ដូសទីពីររបស់អ្នកនៅក្នុងអំឡុងពេល 8 សប្ដាហ៍បន្ទាប់ពីការចាក់ដូសដំបូងរបស់អ្នក។** នេះក៏ព្រោះតែការចំណាយពេលកាន់តែយូររវាងដូសទី 1 និងដូសទី 2 ហាក់ដូចជាបង្កើនប្រសិទ្ធិភាពនៃថ្នាំបង្ការនេះ។ លើសពីនេះទៅទៀត វាក៏កាត់បន្ថយហានិភ័យនៃបញ្ហារលាកសាច់ដុំបេះដូង (myocarditis) ដែលកម្រនឹងកើតមានរួចហើយនោះ។ បុរសវ័យក្មេង (អាយុចន្លោះពី 12 ទៅ 39 ឆ្នាំ) ប្រឈមនឹងហានិភ័យខ្ពស់បំផុតនៃការកើតមានបញ្ហារលាកសាច់ដុំបេះដូងនេះ។
- **ប្រសិនបើអ្នកត្រូវការចាក់ថ្នាំបង្ការឱ្យបានពេញលេញកាន់តែឆាប់នោះ** អ្នកគួរតែទទួលចាក់ដូសទីពីររបស់អ្នកឱ្យបានលឿនជាងមុន៖ យ៉ាងហោចណាស់រយៈពេល 3 សប្ដាហ៍បន្ទាប់ពីការចាក់ដូសទី 1 នៃថ្នាំបង្ការប្រភេទ Pfizer របស់អ្នក និងយ៉ាងហោចណាស់រយៈពេល 4 សប្ដាហ៍បន្ទាប់ពីការចាក់ដូសទី 1 នៃថ្នាំបង្ការប្រភេទ Moderna របស់អ្នក។ ឧទាហរណ៍នៃចំណុចនេះ គឺប្រសិនបើមានការរីករាលដាលនៅក្នុងសហគមន៍តាមទីកន្លែងដែលអ្នករស់នៅ ធ្វើការ ឬធ្វើដំណើរកម្រិតខ្ពស់ ហើយប្រសិនបើអ្នកប្រឈមហានិភ័យខ្ពស់ក្នុងការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ឬប្រសិនបើអ្នកត្រូវការវាសម្រាប់ការធ្វើដំណើរ ការងារ ឬសាលារៀន។
- សូមពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នកមិនប្រាកដថា តើពេលណាមួយដែលល្អបំផុតសម្រាប់ស្ថានភាពរបស់អ្នកនោះ។

**ប្រសិនបើអ្នកស្របតាមចំណុចណាមួយដូចខាងក្រោមនេះ៖**

- មានប្រព័ន្ធភាពស៊ាំចុះខ្សោយកម្រិតមធ្យម ឬធ្ងន់ធ្ងរ
- មានអាយុចាប់ពី 65 ឆ្នាំឡើងទៅ
- អាយុចន្លោះពី 5 ទៅ 11 ឆ្នាំ



**អ្នកគួរតែទទួលចាក់ដូសទីពីររបស់អ្នកឱ្យបានលឿនជាងមុន** - យ៉ាងហោចណាស់រយៈពេល 3 សប្ដាហ៍បន្ទាប់ពីចាក់ដូសទី 1 នៃថ្នាំបង្ការប្រភេទ Pfizer របស់អ្នក និងយ៉ាងហោចណាស់រយៈពេល 4 សប្ដាហ៍បន្ទាប់ពីចាក់ដូសទី 1 នៃថ្នាំបង្ការប្រភេទ Moderna របស់អ្នក។

សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ វិធីទទួលការចាក់ថ្នាំបង្ការ។